# គណបក្សប្រឆាំង

គណបក្សប្រឆាំង សំដៅដល់គណបក្សទាំងឡាយណាដែលនៅក្រៅរដ្ឋាភិបាល។ តែអត្ថន័យនៃគណបក្សប្រឆាំងមិនមែនថានៅក្រៅរដ្ឋាភិបាលតែប៉ុណ្ណោះទេ តែវានៅត្រង់តើគេនៅក្រៅរដ្ឋាភិបាលធ្វើអ្វី? និយមន័យដើមដែលបង្ហាញពីន័យត្រង់នៃពាក្យគណបក្សនយោបាយ គឺសំដៅដល់ក្រុមមនុស្សដែលមាន គំនិត ទស្សនៈ មនោគមវិជ្ជាស្រដៀង ឬប្រហែលគ្នាទៅលើរបៀបនៃការដឹកនាំ និងដោះស្រាយបញ្ហាប្រទេសជាតិ។ ឈរលើគោលនេះ សួរថាចាំបាច់អ្វីត្រូវបង្កើតជាគណបក្សនយោបាយថ្មីៗជាបន្តបន្ទាប់ទៀត បើមានគណបក្សចាស់ៗមួយចំនួនរួចស្រេចទៅហើយ? ក្នុងន័យត្រឹមត្រូវគណបក្សដែលបង្កើតក្រោយៗ ត្រូវតែជាគណបក្សដែលមានទស្សនវិស័យក្នុងការដឹកនាំ និងដោះស្រាយបញ្ហាប្រទេសជាតិ មិនស្របនឹងគណបក្សដែលកំពុងកាន់អំណាចផង និងមិនស្របនឹងគណបក្សប្រឆាំងដែលមានស្រាប់ផង បើពុំដូច្នោះទេមិនដឹងថា បង្កើតមកដើម្បីជាប្រយោជន៍អ្វីដល់ប្រជាពលរដ្ឋឡើយ។

នៅសហរដ្ឋអាមេរិក ដំបូងឡើយគេឃើញមានគណបក្សនយោបាយកើតឡើងច្រើនដែរ តែចុងក្រោយ យើងឃើញគណបក្សនយោបាយរត់ចូលតាមប៉ូលតែពីរ មួយគឺគណបក្សដែលកំពុងដឹកនាំរដ្ឋាភិបាល និងម្ខាងទៀតគឺគណបក្សប្រឆាំង ដែលមានសម្លេងឆ្នោតគាំទ្រប្រដមប្រសងគ្នានឹងគណបក្សឈ្នះឆ្នោតដែរ។ គេច្បាស់ណាស់ថា បើមិនមានទស្សនវិស័យថ្មី ប្លែក ប្រសើរជាងគណបក្សដែលមានរួចទេ គឺគេមិនដឹងថាបង្កើតមកដើម្បីអ្វីឡើយ។ គណ-បក្សដែលទទួលបានសម្លេងឆ្នោតគាំទ្រគំនិត មិនគ្រប់ដើម្បីឈានទៅបង្កើតរដ្ឋាភិបាលបានក្លាយជាគណបក្សប្រឆាំង។ យើងអាចមើលឃើញថា ការប្រឆាំងរបស់គេគឺគ្រាន់តែពួកគេប្រកួតប្រជែងទស្សនវិស័យក្នុងការដឹកនាំប្រទេសតែប៉ុណ្ណោះ ក្នុងន័យថា បើគណបក្សកំពុងកាន់រដ្ឋាភិបាលមិនបានបំពេញតួនាទីរបស់ខ្លួនដោយប្រសិទ្ធភាព ហើយបើគណបក្សប្រឆាំងអាចឆ្លើយតបនឹងបញ្ហានោះប្រកបដោយប្រសិទ្ធភាពជាង នោះប្រជាពលរដ្ឋមុខតែប្តូរទិសគាំទ្រមិនខាន។ តែក៏មិនមែនក្នុងន័យប្តូរដោយបញ្ច្រាស់ទិសគ្នានោះដែរ គឺគណបក្សទាំងពីរសុទ្ធតែជាគណបក្សប្រជាធិបតេយ្យ គ្រាន់តែគេមានទស្សនវិស័យក្នុងការអភិវឌ្ឍប្រទេសខុសគ្នាតែប៉ុណ្ណោះ គឺគណបក្សមួយផ្តោតខ្លាំងលើវិស័យមួយ ឯគណបក្សមួយទៀតផ្តោតខ្លាំងលើវិស័យផ្សេងមួយទៀត គឺគេចេញមុខមកប្រលងគ្នាថា តើដឹកនាំប្រទេសតាមផ្លូវណាទើបរីកចម្រើនលឿនជាង។ គេមិនមែនប្រឆាំងដើម្បីទទួលបានឈ្មោះថាប្រឆាំងឡើយ គឺមិនបានន័យថា រាល់របៀបនៃការដោះស្រាយបញ្ហា ឬទស្សនវិស័យក្នុងការដឹកនាំជាតិរបស់

គណបក្សប្រឆាំង សុទ្ធតែដាក់សញ្ញាផ្ទុយនឹងគណបក្សដែលកំពុងដឹកនាំរដ្ឋាភិបាលរហូតនោះឡើយ។ ផ្ទុយទៅវិញគណបក្សប្រឆាំងដែលមានសមាជិក ជាតំណាងរាស្ត្រនៅក្នុងសភា បានដើរតួនាទីជួយផ្ដល់យោបល់ និងជួយកែតម្រង់រដ្ឋាភិបាលក្នុងន័យរិះគន់ កែលំអដើម្បីការរីកចម្រើនជាតិគឺគណបក្សប្រឆាំងដើរតួនាទីយ៉ាងសំខាន់ក្នុងការឃ្លាំមើលដំណើរការចាត់ចែងកិច្ចការប្រទេសជាតិរបស់បក្សកាន់អំណាច មិនមែនខុសក៏ប្រឆាំង ត្រូវក៏ប្រឆាំងនោះទេ។ មិនមែនប្រឆាំងព្រោះត្រឹមគំនិតម្ខាងទៀត មិនមែនជាគំនិតរបស់ក្រុមខ្លួននោះទេ។

ដោយឡែកគណបក្សប្រឆាំងនៅស្រុកខ្មែរយើងវិញ។ គណបក្សសង្គ្រោះជាតិ ដែលកើតពីគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ហាក់ដូចជា “ទទួលបាននាមជាគណបក្សប្រឆាំងពីកំណើតមកតែម្ដង” ឬអាចនិយាយបានថា កូនគេនោះកើតមកភ្លាមត្រូវបានម្ដាយដាក់ឈ្មោះឲ្យថា “ប្រឆាំង” តែម្ដង តែមិនមែនមកពីគេមានធម្មជាតិពីកំណើតជាអ្នកប្រឆាំងទេ គឺមានត្រឹមឈ្មោះ។

ក្រៅពីប៉ះអីក៏ប្រឆាំង គឺទោះជាគេត្រូវខ្លះក៏នៅតែប្រឆាំង តែប្រឆាំងនោះទៀតសោត ក៏មិនបានបំពេញលក្ខខណ្ឌថា ពេលបដិសេធគំនិតគេ ត្រូវបង្ហាញគំនិតខ្លួនឯងដែលប្រសើរជាងនោះឡើយ គឺត្រឹមថាយកៗហើយក៏ទៅបាត់។ បើគេកាប់ព្រៃឈើលក់ខ្ទេច គណបក្សប្រឆាំង (ប្រឆាំងដោយបានឈ្មោះថា លោកប្រឆាំង) ក៏ស្រែកថាចាំដល់ពេលគេឈ្នះឆ្នោត គេសន្យាថានឹងមិនកាប់ព្រៃឈើ បើគេមិនអើពើ នឹងវិបត្តិដីធ្លី គណបក្សប្រឆាំងក៏ថាគេនឹងមិនឲ្យមានវិបត្តិដីធ្លីដែលកើតពី ការរំលោភរបស់អ្នកមានលុយមានអំណាចទៀតទេ។ បើឃើញជនអន្តោប្រវេស្តន៍យួនហូរចូលគគ្រឹកខុសច្បាប់ លោកដែលមានឈ្មោះ លោកប្រឆាំងក៏ថា នឹងដេញជនអន្តោប្រវេស្តន៍យួនទៅវិញឲ្យអស់។ ទាំងអស់នេះហើយហៅថាប្រឆាំងឲ្យតែបានប្រឆាំង។ លោកនាយករដ្ឋមន្ត្រីតែងតែឌឺទៅវិញជារឿយៗថា អាអ្នកថាបានតែថា អាអ្នកធ្វើនៅតែធ្វើ! ឆ្កែនៅតែព្រុសមនុស្សនៅតែដើរ! ជាដើម។

លើសពីប្រឆាំងឲ្យតែបានប្រឆាំង គឺប្រឆាំងដើម្បីគ្រាន់តែទាញយកបានសមានចិត្តប្រជាពលរដ្ឋ ដែលកំពុងតែត្រដររស់គណបក្សប្រឆាំងសង្គ្រោះជាតិ ក៏ទទួលបានងារជាគណបក្សប្រឆាំង ដាច់មុខតែម្ដង គឺទោះបីជាមេដឹកនាំរបស់បក្សនេះ បែរទិសដៅរបស់ខ្លួន ១៨០ ដឺក្រេ (ស្មើនឹងស្តោះហើយលេបវិញ) ក៏ដោយ ក៏គេនៅតែមានឈ្មោះជាគណបក្សប្រឆាំងដដែល។ ពិតជាគណបក្សប្រឆាំងផ្ដាច់មុខរបស់គេមែន។

ប្រឆាំងដើម្បីតែប្រឆាំង ដោយគ្មានទស្សនវិស័យច្បាស់លាស់ខុសពីបក្សកាន់អំណាច ជារឿងមួយដែលមិនត្រូវហៅថាជាគណបក្សប្រឆាំងទៅហើយ តែរឿងមួយទៀតនោះ គឺប្រជាពលរដ្ឋនៅតែ លើកទូលបក្សនោះថាជា "គណបក្សប្រឆាំងធំបំផុត និងតែមួយគត់" ដដែល។ ហេតុអ្វី? ព្រោះថាលោកម្នាក់នោះ មានឈ្មោះថាលោកប្រឆាំង។ គួរឲ្យអស់សំណើចថែមទៀតនោះ គឺលោកប្រឆាំងនោះមានឈ្មោះថា លោកជួយ លោកសង្គ្រោះថែមទៀត ហើយគ្រាន់តែប៉ុណ្ណឹង ក៏គ្រប់គ្រាន់ឲ្យប្រជាពលរដ្ឋខ្មែរដ៏សែនឡេឡឺគាំទ្រគេបានទៅហើយ។

ដូចបានបង្ហាញជូនខ្លះរួចមកហើយថា បើចង់បដិសេធគំនិតណាមួយរបស់គេ លុះត្រាតែយើង ក្រៅពីផ្ដល់នូវអំណះអំណាង ត្រូវផ្ដល់នូវគំនិតថ្មីមួយដែលប្រសើរជាងមកជំនួស នោះទើបមានការផ្លាស់ប្ដូរ ដែលនាំទៅរកការរីកចម្រើនបាន។ បើត្រឹមតែលើកសញ្ញាផ្ទុយ ដាក់ទល់នឹងគ្រប់ទង្វើរបស់រដ្ឋាភិបាល នោះវាមិនមែនជាគណបក្សប្រឆាំងដែលមានប្រសិទ្ធភាពឡើយ។ ព្រោះថា គេនោះក៏គ្មានទស្សនវិស័យ ថែមទាំងគ្មានបេះដូងស្មោះត្រង់ក្នុងការជួយចូលរួមធ្វើឲ្យប្រទេសជាតិចម្រើនឡើយ គេទាមទារយកត្រឹមស្លាកឈ្មោះជាគណបក្សប្រឆាំង ដើម្បីទាញយកសន្លឹកឆ្នោតពីប្រជាពលរដ្ឋ ដែលកំពុងតែឈឺចាប់ឲ្យបោះឆ្នោតដើម្បីឲ្យខ្លួនបានទទួលលាភសក្ការៈតែប៉ុណ្ណោះ

ឯបញ្ហាប្រទេសជាតិនៅស្រែកេកស្រកាកដដែល។

គណបក្សសង្គ្រោះជាតិយកផ្លាកជាគណបក្សប្រឆាំងធំបំផុត និងតែមួយគត់ ទ្រាប់លើក្បាល ប្រជាពលរដ្ឋខ្មែរដើម្បីទទួលបានកៅអីសភា ៥៥ កៅអីជារឿងមួយហើយ គឺប្រឆាំងទាំងមិនដឹងទិសតំបន់ ដឹងត្រឹមដាក់សញ្ញាផ្ទុយទល់នឹងរដ្ឋាភិបាល នេះហៅថា "ប្រឆាំងដើម្បីប្រឆាំង"។ លុះដល់ពេលគេប្ដូរទិសនយោបាយគេ ពីប្រឆាំងដាច់ខាតបុគ្គលលោក ហ៊ុន សែន ដល់ថ្នាក់ មានស៊ីអត់សែន មានសែនអត់ស៊ីទៅជា បាទសម្ដេច! បាទសម្ដេច! ក៏គេនៅតែមានស្លាកបក្សប្រឆាំងពាក់នៅនឹង ក របស់គេដដែល នេះហៅថា "ប្រឆាំងតាំងពីពេលកើតមក"។

លោក ម៉ៅ មុន្នីវណ្ណ បានចាកចេញពីលោក សម រង្ស៊ី មកចូលជាមួយលោក កឹម សុខា ព្រោះតែយល់ថាគណបក្ស សម រង្ស៊ី ជាទីងងឹត ដូច្នេះគឺគេចេញពីទីងងឹតចូលទៅទីភ្លឺ។ លោក កឹម សុខា និយាយថាទីងងឹតមានតែចោរទេ ដែលចូលចិត្ត ដូច្នេះវាស្មើនឹងលោក កឹម សុខា ថាអោយលោក សម រង្ស៊ី ថាជាក្រុមចោរ។ មិនបានប៉ុន្មានផង លោក កឹម សុខា ក៏ដឹកនាំបក្ខពួករបស់គាត់ពីទីភ្លឺ ទៅចូលក្នុងទីងងឹតដែលជាកន្លែងសម្រាប់ពួកចោរដែរ។ ក្រោយពីច្រឡំបល់លែងដឹងងងឹតភ្លឺចូលគ្នារួចមកលោក សម រង្ស៊ី និងលោក កឹម សុខា នាំគ្នាស្រែកថាឲ្យលោក ហ៊ុន សែន ថាជាចោរលួចជាតិលួចធន្ទះប្រជាពលរដ្ឋបម្រើអាយ៉ងយួន។ តែឥឡូវទាំងលោក សម រង្ស៊ី និងលោក កឹម សុខា បានដឹកនាំហ្វូងរបស់ខ្លួន ទៅចូលជាមួយចោរលក់ជាតិដែលគេធ្លាប់ថាបាត់ទៅហើយ។ ម្លឹងៗហើយ គេនៅតែនិយាយថា គេមានជំហរឹងមាំមិនផ្លាស់ប្ដូរទៀត។

មិនខុសពីរឿងប្រឆាំងតាំងពីកើតមកនេះដែរ គឺរឿងគេហៅគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ថាអាយ៉ង។ ពេលសម្ព័ន្ធកើតមករៀមច្បងដែលបានកើតមុន ពេលដែលបានឃើញលក្ខណៈមានកំណើត (ទ្រង់ទ្រាយបញ្ជាក់ថាប្រឆាំងពិតប្រាកដមែនរបស់សម្ព័ន្ធ) គេក៏ហៅសម្ព័ន្ធថា អាយ៉ងៗតែម្ដង ក្នុងន័យថា ក្មេងម្នាក់នេះកើតមក ត្រូវបានគេដាក់ឈ្មោះគ្នាថា អាយ៉ង ទើបដើរទៅណាមកណាគេហៅថា អាយ៉ងៗបែបនេះ។ គឺគេហៅដើម្បីសម្លាប់។

កាលពី ៨ ឆ្នាំមុន ពេលកើតមកភ្លាម សម្ព័ន្ធបានអោបជាប់មកជាមួយ នូវគោលធំៗ ៤ គឺ (១) គោលដៅរួមគឺឈានទៅសម្រេចសុបិនរួម "មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់"។ ដែលគោលដៅនេះអាចសម្រេចទៅបាន តាមរយៈការឈានទៅយកយន្តការទាំង ៨ ចំណុច ជាយន្តការក្នុងការកាត់បន្ថយអំណាចរដ្ឋក្នុងន័យដើម្បីឲ្យប្រជាពលរដ្ឋមានអំណាច ទៅចងកម្រិតអំណាចនាយករដ្ឋមន្ត្រី ដែលតាំងតែពីដើមរៀងមកអង្គុយនៅក្រៅសំណាញ់ច្បាប់។ (២) ចំណុចចាប់ផ្ដើមរបស់យើង គឺចេញពីការពន្យល់ប្រជាពលរដ្ឋ ឲ្យមានការយល់ដឹងលើគោលធំៗបីគឺ ប្រជាធិបតេយ្យ/នយោបាយ ការទាញយកប្រយោជន៍ពីកិច្ចបដិបត្តិព្រះធម៌ និងសីលធម៌សង្គម ដើម្បីឈានទៅផ្លាស់ប្ដូរផ្នត់គំនិតប្រជាពលរដ្ឋ ហើយប្រែក្លាយជាពលរដ្ឋខ្លឹម និងប្រកបដោយគុណភាព។ (៣) ឥរិយាបថនយោបាយ គឺឈរលើបាតគ្រឹះសុចរិត នាំគ្នាមកចូលរួមជួយដោះស្រាយបញ្ហាជាតិ ដោយបេះដូងស្មោះត្រង់ពិតប្រាកដមែន មិនមែនដើម្បីប្រយោជន៍ផ្ទាល់របស់បុគ្គលឡើយ។ (៤) ធនធានមនុស្សត្រូវតែជាបុគ្គលដែលមានទាំងក្បាល (Head) បេះដូង (Heart) និងកណ្ដាប់ដៃ (Hand) គឺមានទាំងទស្សនវិស័យមុតស្រួចក្នុងការដោះស្រាយបញ្ហាជាតិ មានទាំងបេះដូងថ្លាស្អាតមិនលោភមកលើទីលាននយោបាយ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន តែដោយគឺឈឺឆ្អាលចំពោះសុខទុក្ខរបស់ប្រជាពលរដ្ឋពិតប្រាកដ និងប្រកប ដោយការប្ដេជ្ញាចិត្តខ្ពស់ ក្នុងការនាំយកទស្សនវិស័យរបស់យើងមកអនុវត្ត។ ពួកយើងទន់ភ្លន់តែដាច់ខាត! ទន់ភ្លន់តែរឹងមាំ! មិនត្រឹមតែរឹងទេ ថែមទាំងស្វិតថែមទៀត។ បើគម្រាមយើង នោះពួកយើងអាចខ្លាចដែរ ព្រោះស្បែកពួកយើងស៊ូនឹង គ្រាប់សំណមិន បាន តែបើឲ្យយើងឈប់ គឺមិនឈប់ដាច់ខាត។ ពត់

កាន់តែខ្លាំង ពេលរលាស់ វ៉ៃត្រលប់ទៅវិញ ក៏រឹតតែខ្លាំងលើសដើម ។

មកដល់សព្វថ្ងៃនេះ គោលជំទាំង ៤ របស់ពួកយើងយ៉ាងណា នៅតែយ៉ាងនោះ។ យើងមិនបានប្ដូរចេញពីគោលដើមរបស់យើងសោះឡើយ តែគេនៅតែហៅយើងថា អាយ៉ងដដែល។ ជាពិសេសទោះលោកប្រឆាំងចូលសភាអស់ហើយ ក៏លោកប្រឆាំងនៅតែហៅពួកយើងថាអាយ៉ង។ វាមិនខុសអីពីរឿងទ្រង់ព្រះនាមហៅថា ព្រះសិអាមេត្រី បើទោះគេចាប់បាន ហើយតួអង្គនោះសារភាពថា ខ្លួនបានបោកប្រាស់ក៏ដោយ ក៏នៅតែមានមនុស្សអោនក្បាលក្រាបថ្វាយបង្គំគេដដែល។ ហេតុអ្វី? ព្រោះថាកូនគេនោះ ទ្រង់ព្រះនាមហៅថា ព្រះសិអាមេត្រី។

ស្ថានភាពជាក់ស្ដែងរបស់ខ្មែរយើង វាសឹងតែហួសនឹងនិយាយថា កំពុងតែប្រឈមនឹងគ្រោះថ្នាក់ទៅហើយ ព្រោះថាមិនដឹងដល់ណាទេគ្រោះថ្នាក់នោះ ឮតែថាគ្រោះថ្នាក់នោះរាប់សិបឆ្នាំមកហើយ។ តែវាជាដំណើរនៃការបាត់ពូជសាសន៍ ដែលនៅសេសសល់បន្តិចបន្តួចនេះតែម្ដង។ ប្រព័ន្ធគ្រប់គ្រងប្រទេស ដោយអំណាចប្រមូលផ្ដុំដូចសព្វថ្ងៃ ជាប្រព័ន្ធចាក់ស្រែះ ដែលមានតែបុគ្គលតែប៉ុន្មាននាក់តែប៉ុណ្ណោះ ជាអ្នកកាន់គន្លឹះស្លាប់រស់របស់ជាតិ។ ប្រព័ន្ធប្រមូលផ្ដុំអំណាច មានដៃរវៀម ប្រៀបដូចដៃមឹក លូកទៅកកូរកកាយបញ្ហាដល់តំណាងដែលកៀកនឹងប្រជាពលរដ្ឋបំផុតនៅភូមិឃុំ គឺបក្សចុះដល់មូលដ្ឋានតែម្ដង។ សម័យនេះទៅហើយ មេភូមិនៅដើរកត់ឈ្មោះ នរណាដែលមិនគាំទ្ររបៀបដឹកនាំចាស់គម្រិល របស់ខ្លួនទៀត។ គេតែងតែថាបានប៉ុណ្ណឹងហើយ តើចង់បានប៉ុណ្ណាទៀត? គេក៏អួតថារដ្ឋាភិបាលប្រឹងប្រែងខ្លាំងណាស់ក្នុងការអភិវឌ្ឍប្រទេស។ យើងមិនចង់និយាយទៅកាន់មនុស្សខួរក្បាលជុះស្លែរទាំងនោះ ពីរឿងសមិទ្ធផលជាតិនានា ដែលយកលុយជាតិទៅកសាងក្រោមផ្លាកថាបក្សអ្នកកសាងនោះទេ តែយើងចង់សួរថា តើប្រឹងកសាងប្រទេសដល់ណាទៀត បើបានប៉ុណ្ណឹងទៅហើយ?

កុំថាដល់រឿងខ្ទេចខ្ទីប្រទេសជាតិធំៗ ត្រឹមតែករណីតូចមួយដែលគេយកមកនិយាយលេងសើច តាមតៀមស្រាក៏ល្មមឲ្យទឹកភ្នែករបស់អ្នកដែលមានចិត្តឈឺឆ្អាលរឿងជាតិមែនៗហូរបានដែរ។ ត្រឹមធ្លាក់ប៉ោតក្ដាំង! ក៏ប្រជាពលរដ្ឋលោតរាំបានដែរ! ឱ! ខ្មែរអើយខ្មែរ! យ៉ាប់អីក៏យ៉ាប់យ៉ាងនេះ លោកពលរដ្ឋខ្មែរ? ខ្មែរសព្វថ្ងៃរស់នៅមិនលើសពីសត្វ រាប់តាំងពីរឿងសង្គមកិច្ច រហូតដល់រឿងសីលធម៌ ប្រៀបដូចសត្វរៃរាំច្រៀងៗ លេងបៀរ ផឹកស្រា ចាក់កន្ទុយលេខ ទំនេរៗដេកអេសពោះរកចៃកក្អាកកក្អាយ មើលឪសរឿងថៃ លែងខ្វល់រឿងអនាគតជាតិ។ ចង់គេយកដីជាតិលក់ឯណា ក៏លក់ទៅចង់ប្រជាពលរដ្ឋឯណាឈឺចាប់ យំស្រែកដោយគេរំលោភក៏យំទៅ កុំឲ្យតែមកយកជណ្ដើរផ្ទះអញ។ មួយក្រុមទៀតម៉្ងៃៗ រវល់តែរឿងជំនួញបុណ្យ គេនាំគ្នាបណ្ដាក់ទុនទៅឋានសួគ៌ គេថាគេអ្នកធម៌អ្នកអាថ៌រឿងនយោបាយទុកឲ្យគេទៅចុះ គេដឹងតែពីស្រ៊ូស្រ៊ៈៗ យកមាសទៅបូជានៅគល់ពោធិ៍ ចូលលុយទិញដីធ្វើវត្តនៅឥណ្ឌាដើម្បីបានបុណ្យតែប៉ុណ្ណោះ។ នេះជាក្រុមសាសនាដ៏ងងឹតងងល់។ នៅមួយក្រុមទៀត គឺក្រុមចាំស៊ីលើភាពល្ងង់ខ្លៅរបស់ក្រុមប្រាថ្នាសួគ៌។ គេលួងលោមដោយពាក្យសម្ដីផ្អែមល្ហែម ថាខ្លួនជាអ្នកសាសនាជាក់លាក់ណាស់ គេថាគេជាស្រែបុណ្យ។ ពួកនេះកំពុងតែរួមចំណែកបំផ្លាញជាតិដល់ឫសគល់តែម្ដង។ គេប្រាប់ប្រជាពលរដ្ឋថាធ្វើអ្វីៗ ដេកចាំតែពឹងលើព្រេងសំណាង លែងចេះពឹងក្បាល លែងពឹងកណ្ដាប់ដៃខ្លួនឯង បែរជាសំពះសុំសុខពីគេ។ ក្រុមមួយទៀតនោះមានចិត្តឈឺឆ្អាលចំពោះរឿងប្រទេសជាតិដែរ តែត្រូវបានលោកព្រះនាមទ្រង់ហៅថា លោកប្រឆាំងតាំងពីពេលកើត មកបោក មិនស្វាង។ ពួកគេខ្លះមានតែទឹកចិត្តឈឺឆ្អាលខ្មែរដែរ តែគេខ្វះមូលដ្ឋានក្នុងការពិចារណា បណ្ដាលឲ្យ អ្នកនយោបាយទុច្ចរិត ដែលគ្មានទស្សនវិស័យ បោកប្រាស់រឹរក់ ជាន់ឈ្លីទឹកចិត្ត ម្ដងហើយម្ដងទៀត។

សម្ព័ន្ធកើតមកចន្លោះភាពរីកវរនេះ។ ទាំងរដ្ឋាភិបាល ទាំងបក្សដែលមានផ្លាកឈ្មោះថា បក្សប្រឆាំង ទាំងអង្គការសង្គមស៊ីវិល ទាំងប្រជាពលរដ្ឋជាអ្នកសាសនា ឬជនក្រៅសាសនា ក៏យើងដៅសំដៅទៅទាំងអស់ ដែលក្នុងន័យនេះមិនមែនរូបបុគ្គលទេ ដែលយើងសំដៅទៅ តែគឺអំពើអាក្រក់ទៅវិញទេ។ ថាបក្សកាន់អំណាចចុះដែលត្រាំក្នុងអំណាច លិចទៅក្នុងប្រព័ន្ធប្រមូលផ្តុំអំណាចរើខ្លួនមិនរួចបែរទៅមើល លោកប្រឆាំងលោកសង្គ្រោះ ក៏មិនអើពើរឿងបំបែកអំណាចដែលកំពុងប្រមូលផ្តុំនេះដែរ។ អាស្រ័យហេតុនេះហើយ ទើបក្រុមយើងច្បាស់ថា ពួកយើងក្រុមសម្ព័ន្ធនេះ មិនត្រឹមតែមិនដូចគេនោះទេ តែគឺមិនច្រលំជាមួយគេតែម្តង។ ពួកយើងចូលរួមដៃគ្នាដាំបណ្តុះអំពើល្អដោយដៃម្ខាង ដៃម្ខាងទៀត វាយអំពើអាក្រក់មិនឲ្យងើបមុខរួច។ យើងកំពុងធ្វើសកម្មភាពដើម្បីកែតម្រង់ ដុសខាត់ដាំបណ្តុះសីលធម៌ សង្គមខ្មែរមកវិញ។

បើទោះបីជាបានទទួលសម្លេងគាំទ្រគ្រប់គ្រាន់ក្នុងការដឹកនាំប្រទេស ឬក៏មិនបាន ក៏របៀបធ្វើនយោបាយបែបពួកយើងនេះ មិនបានបំផ្លាញជាតិសោះឡើយ មានតែផ្តល់នូវមូលដ្ឋានចំណេះដឹងដល់ប្រជាពលរដ្ឋតែប៉ុណ្ណោះ។ ទង្វើទាំងនេះ ទោះមានផ្លាកឈ្មោះជាបក្សប្រឆាំង ឬជាអាយ៉ងវាមិនសំខាន់ទៀតទេ តែសំខាន់គឺក្រុមយើងឈរតាំងពីកើតមក តែនៅលើភាពត្រឹមត្រូវ ហើយធ្វើសកម្មភាពដើម្បីកំណត់តម្លៃរបស់ក្រុមយើងដោយខ្លួនយើង ដោយមិនចាំបាច់ អ្នកដទៃមកកំណត់តម្លៃឡើយ។

ទទួលស្គាល់ ឬមិនទទួលស្គាល់ មិនសំខាន់ តែអត្ថិភាពរបស់សម្ព័ន្ធមាននៅលើទឹកដីខ្មែរហើយមនោគមវិជ្ជារបស់ក្រុមយើង កំពុងតែសាយភាយហើយ។ កាលណាអ្នកមិនព្រមបើកភ្នែកនោះវាមានន័យត្រឹមថា អ្នកមិនបើកភ្នែក តែវាមិនមែនមានន័យថា មិនមានពួកយើង នៅចំពោះមុខអ្នកឡើយ៕

## ឆ្កែព្រៃ និងឆ្កែស្រុក

ឆ្កែស្រុកមួយបានមកចងមិត្តនឹងឆ្កែព្រៃមួយ។ ឆ្កែស្រុកបានបបួលឆ្កែព្រៃឲ្យទៅនៅជាមួយ។ ឆ្កែព្រៃសួរពីការងារដែលត្រូវធ្វើ។ ឆ្កែស្រុកក៏រៀបរាប់ថា៖

"ការងារស្រួលណាស់ គឺយាមផ្ទះ និងរត់ចាប់សត្វពេលម្ចាស់នាំទៅព្រៃ ហើយដល់ម៉ោងគេដាក់បាយឲ្យស៊ីហើយដេក"

"ការងារស្រួលណាស់! អូហ៍! ចុះស្អីដែលព័ទ្ធកឯងនោះ?" ឆ្កែព្រៃសួរ។

"នេះគេហៅថាប្រឡៅក! គេឲ្យពាក់ចំណាំ ថាយើងជារបស់គេ" ឆ្កែស្រុកតប។

"ឱសម្លាញ់! ប្រឡៅកនេះចង្រៃណាស់។ បើកាលណាពាក់ប្រឡៅកគេហើយ ត្រូវតែធ្វើតាមគេប្រើតាមគេបញ្ជា ស៊ីក៏តាមគេឲ្យ មិនមែនតាមយើងឃ្លានទេ គ្មានសេរីភាពទេ! គ្នាសុខចិត្តស៊ីអត់ស៊ីឃ្លានតាមសម្មាអាជីវៈ មិនប្រាថ្នាប្រឡៅកទេ!!!" ឆ្កែព្រៃតបហើយក៏ដើរចេញទៅ។

ខណៈពេលដែលមនុស្សសុំនឹងការត្រូវពឹងគេ នោះគេនឹងមិនអាចហែករនាំងនោះចេញឡើយវាទៅជាសុខចិត្ត បន្ថែមភាពជាទាសកររបស់ខ្លួនជារឿយៗ ដើម្បីប្តូរយកសេចក្តីសុខក្លែងក្លាយ ដែលស្ថិតនៅក្នុងកណ្តាប់ដៃរបស់គេ។ ឥស្សរៈមានតម្លៃមិនអាចកាត់ថ្លៃបាន បើអ្នកលក់ឥស្សរៈរបស់អ្នកហើយ អ្នកអស់តម្លៃជាមនុស្សហើយ វានៅសល់ត្រឹមឈ្មោះថា កញ្ជះ!

ឥស្សរៈ គឺការមិនរណប! ការមិនលក់! ការសម្រេចចិត្តធ្វើទៅតាមឧត្តមគតិរបស់ខ្លួន វាអាចឲ្យ យើងត្រូវធ្វើដំណើរលើវិថីនោះតែម្នាក់ឯងនៅពេលខ្លះ តែមិនបានន័យថាយើងឯកោទេ! សាកនឹកថយក្រោយបន្តិចទៅមើល ថាតើរាល់ពេលមានអារម្មណ៍ឯកោ គឺជាពេលដែលយើងនៅតែម្នាក់ឯងមែនទេ? មិនមែនទេ! ពេលច្រើនដងណាស់ដែលយើងឯកោក្នុងចំណោមហ្វូងមនុស្ស ដែលយើងចូល

ជិតមិនបានទៅវិញទេ។ ហេតុអ្វីទើបចូលជិតមិនបាន? ម្តេចមិនដើរចូលទៅរកគេទៅ? ចូលទៅបានត្រឹមតែរូបកាយតែប៉ុណ្ណោះ តែបើកំពស់ទឹកចិត្តខុសគ្នា យើងច្បាស់ជាទទួលអារម្មណ៍ថានៅឆ្ងាយពីគ្នាណាស់ ហើយមានមនុស្សតិចណាស់ដែល ហ៊ានបញ្ចេញយោបល់ជំទាស់នឹងភាពលំអៀង ជំទាស់នឹងកង្វះខាតណាមួយ ព្រោះតែការជំទាស់នោះនឹងនាំបញ្ហាដល់គេ និងម្យ៉ាងគេយល់ថាមិនមានប្រយោជន៍ ព្រោះគេនឹងមិនទទួលយកការរំលឹកដាស់តឿននោះ។ ដូច្នេះចាំសិនទៅ! តើចាំដល់វាជ្រុលកែលែងកើតទៅឬ? បើយើងស្រលាញ់គេពិតមែន យើងប្រាកដជាអោបដៃនៅស្ងៀម ឲ្យគេធ្វើដំណើរទៅរកកំហុស ដោយមិនកែមិនបានឡើយ។ ហើយក៏មានមនុស្សជាច្រើន មិនហ៊ានសូម្បីត្រឹមតែគិតបែកផ្លូវផ្សេង និងបង្ហាញមធ្យោបាយថ្មី ក្នុងការដោះស្រាយបញ្ហាចាស់ៗ។ ឥស្សរៈ គឺការមិនស្ថិតក្រោមឥទ្ធិពលរបស់បរិយាកាសជុំវិញ ទាំងឥទ្ធិពលសង្គម ប្រពៃណី ឬអំណាចពិសេសណាមួយ។

ឥស្សរៈ មិនចងជាប់ជាមួយជុំបាយទេ។ បើយើងចេះតែរំពែរកនុយជារឿយៗ លែងអីគង់នឹងមិនជាប់សន្ទូច? បើត្រឹមចង់បានបាយហូប ដូចជាមិនមែនជាហេតុផលទៅធ្វើជាកញ្ជះគេសោះ ឬក៏ដើម្បីរក្សាជីវិតនេះ ក៏ចេះតែទ្រាំទៅ? បើដូច្នេះមានរឿងត្រូវសួរទៀតហើយថា តើការរក្សាជីវិតនេះឬដែលអ្នកតម្កល់ជាទីសក្ការៈ រហូតឈានទៅ "ធ្វើខ្លួន" ជាទាសករ? រស់បែបត្រឹមមានដង្ហើមដកនោះឬដែលសំខាន់ចំពោះអ្នក? បើគ្មានការងារមានតម្លៃជាឧត្តមគតិធ្វើទេ រូបកាយមួយនេះអាចប្រៀបជាសម្បកធុលាមកតែប៉ុណ្ណោះ តម្លៃមនុស្ស ស្ថិតនៅលើតម្លៃនៃការងាររបស់គេ។ ស៊ូនៅក្នុងស្ថានភាពលំបាក ជាជាងនៅក្នុងលក្ខខណ្ឌដែលស្រួលតែកាយ តែត្រូវធ្វើខ្លួនជាទាសករជាកញ្ជះ។

មានតែសេរីភាពពីខាងក្រៅ រួមជាមួយឥស្សរៈពីខាងក្នុងតែប៉ុណ្ណោះ ដែលនាំឲ្យសម្បជញ្ញៈមនុស្សរីកចម្រើនឡើងៗ។

## គតិផ្សេងៗ

ចលនាបដិវត្តន៍ដែលទទួលជោគជ័យលើលោក គឺជាចលនាដែលកើតឡើងក្នុងគោលបំណងតែមួយគត់ គឺទាំងអស់គ្នាដើម្បីទាំងអស់គ្នា។

Successful revolutionary movements in the world are those based on only one goal "all for all".

បើយើងមើលមនុស្សតែតាមកាយវិការ និងវាចា ដោយមិនមើលពីចិត្តរបស់គេទេ មួយជីវិតនេះយើងងាប់តែហ្នឹងត្រូវគេបោក។

If we judge people based on their activities and words and do not consider their mind as well, you are vulnerable to being taken advantage of for your whole life.

មាតុភូមិមួយនេះ មិនអាចក្លាយជាកន្លែងសុខសាន្តសម្រាប់ពួកយើងរស់នៅទេ ប្រសិនណាពួកយើងមិនបានចូលរួមធ្វើដោយកណ្តាប់ដៃរបស់ពួកយើងទេនោះ។

This motherland cannot be a happy and prosperous place for all of us if we do not jointly and consciously make it so with our own hands.

## ស្វែងយល់បន្ថែម

(១). វិទ្យុសំបុកឃ្មុំ FM105 MHz ភ្នំពេញ: ម៉ោង ២ ដល់ម៉ោង ៣ រសៀល
(២). គេហទំព័រ: www.camldp.org
(៣). YouTube: ខឹម វាសនា ឬ Khem Veasna
(៤). Paltalk: Room Koun Khmer និង/ឬ
(៥). សារអេឡិចត្រូនិក: camldp3@gmail.com